អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
លេខ :..................អ.ជ.ប.ជ.អ

# សេចក្តីសម្រេចចិត្ត
# នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# លើកទី២ ឆ្នាំ២០២១ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២១ បានដំណើរការរយៈពេលមួយព្រឹកពេញ នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ នៅសាលប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមបណ្តាញវីដេអូ កម្មវិធីZoom ដោយមានការចូលរួមពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ តំណាងអង្គការ UNAIDS និងអង្គការសង្គមស៊ីវិល សរុបចំនួនប្រមាណ២០០រូប។

ក្នុងរយៈពេលពីរឆ្នាំនៃការប្រយុទ្ធប្រឆាំងនឹងកូវីដ-១៩នេះ កម្ពុជាបានក្លាយជាប្រទេសឈានមុខមួយនៅអាស៊ី និងក្នុងពិភពលោក ដែលបង្ហាញថា ការការពារសុខភាពសាធារណៈមានសារៈសំខាន់បំផុតសម្រាប់ធានាសន្តិសុខសង្គម និងសេដ្ឋកិច្ច ព្រមទាំងជំរុញឱ្យឈានទៅសម្រេចក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (Cambodia SDG)។

ប៉ុន្តែដោយឡែក ជំងឺអេដស៍នៅមិនទាន់សាបរលាបអស់ទេ នៅលើពិភពលោក រួមទាំងប្រទេសកម្ពុជាយើងដែរ។ ជំងឺអេដស៍នៅតែជះឥទ្ធិពលប្រកបដោយហានិភ័យខ្ពស់ដល់សង្គម និងការអភិវឌ្ឍជាតិ។ ជាង៣០ឆ្នាំកន្លងទៅ ប្រទេសកម្ពុជាបានទទួលមេរៀន និងបទពិសោធន៍យ៉ាងច្រើនក្នុងការប្រយុទ្ធនឹងការរីករាលដាលនៃមេរោគអេដស៍។ យ៉ាងណាក៏ដោយ ដើម្បីឈានទៅដល់គោលដៅឆ្នាំ២០២៥ និងកាត់បន្ថយការឆ្លងថ្មីឱ្យតិចជាង២៥០ករណីក្នុងមួយឆ្នាំ កម្ពុជាចាំបាច់ត្រូវតែអនុវត្តគោលនយោបាយ និងចាត់វិធានការថ្មីៗដែលមិនធ្លាប់មានពីមុនមក។

ក្នុងបរិបទនៃការឆ្លងកាត់ពីកម្មវិធីអន្តរកាលឆ្ពោះទៅកាន់ចីរភាពនៃកម្មវិធីអេដស៍ ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានភារកិច្ចអនុវត្តសេចក្តីអំពាវនាវដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឱ្យយើងទាំងអស់គ្នា ចូលរួមជាចរន្តជាតិតែមួយ នាំគ្នាសម្រេចឱ្យបាននូវគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ តាមមុខនាទីជាយុទ្ធសាស្ត្រ និងនៅតាមមូលដ្ឋានរៀងៗខ្លួន។ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញចរន្តជាតិតែមួយនេះ ជាត្រីវិស័យ

ចង្អុលទិស លើបទអន្តរាគមន៍២ផ្នែក ដែលមានសារៈសំខាន់ និងមានទំនាក់ទំនងរវាងគ្នានឹងគ្នា ក្នុងការពង្រឹងភាពជាម្ចាស់ដូចខាងក្រោម ៖

ក) ការពង្រីកដែនគ្របដណ្តប់ និងប្រសិទ្ធភាពនៃកម្មវិធីនានា ឱ្យបានទៅដល់ប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ និង

ខ) ការពង្រឹងប្រព័ន្ធជាតិឱ្យឆ្លើយតបនឹងជំងឺអេដស៍ ប្រកបដោយថាមពល និងបរិយាបន្ន។

ក្នុងរយៈពេលបួនឆ្នាំខាងមុខ កម្ពុជាត្រូវតែចាប់យកឱកាស ដើម្បីលុបបំបាត់មេរោគអេដស៍ និងជំងឺអេដស៍ ដែលនៅតែយាយីដល់សុខភាពសាធារណៈយ៉ាងធ្ងន់ធ្ងរ ដោយត្រូវ ៖

- ពង្រឹងប្រព័ន្ធប្រទេស (Country System) ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យម្ចាស់ការក្នុងការឆ្លើយតបទាន់ពេលចំពោះរាល់បញ្ហាដែលកើតមានឡើង។
- បង្កើនការវិនិយោគឱ្យកាន់តែទូលំទូលាយ លើវិធានការដែលប្រកបដោយប្រសិទ្ធភាពខ្ពស់។
- ធ្វើការក្នុងភាពជាដៃគូជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងប្រជាជនគន្លឹះ និងតំណាងអ្នកផ្ទុកមេរោគអេដស៍ ក្នុងគោលបំណងធានាថាគោលនយោបាយ និងអន្តរាគមន៍ទាំងអស់ត្រូវបានអនុវត្តយ៉ាងរលូន ព្រមទាំងដោះស្រាយរាល់វិសមភាព ដែលកំពុងរារាំងវឌ្ឍនភាព ក្នុងទិសដៅឈានទៅបញ្ចប់ជំងឺអេដស៍តាមកាលកំណត់។

នៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ និងខេត្ត ត្រូវដាក់ចេញនូវយន្តការចម្បងក្នុងការណែនាំ ជំរុញការគាំទ្រ និងសម្របសម្រួលជាលក្ខណៈពហុវិស័យ ពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រ ព្រមទាំងវិធានការនានា ដើម្បីធានាជោគជ័យនៃការបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥។

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ បានឯកភាពដាក់ចេញនូវសេចក្តីសម្រេចតាមខ្លឹមសារដូចខាងក្រោម ៖

១) ស្នើឱ្យមានកិច្ចសហការពេញលេញពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងផែនការ ឱ្យបន្តគាំទ្រ និងតាមដានការអនុវត្តវិធានការទាំង៦របស់រាជរដ្ឋាភិបាល ឱ្យបានសម្រេចតាមខ្លឹមសារនៃលិខិតលេខ២១៣សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

២) ស្នើឱ្យមានកិច្ចសហការពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ណែនាំដល់រដ្ឋបាលរាជធានី ខេត្ត ជាពិសេសគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី និងខេត្តគោលដៅ រួមមានរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប (Fast-Track

Cities) ស្តីពីការអនុវត្តផែនការសកម្មភាព និងថវិកាប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងដែនសមត្ថកិច្ច ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

៣) ស្នើឱ្យមានកិច្ចសហការពេញលេញពីរាជធានី ខេត្តទាំងអស់ ឱ្យបង្កើនការធ្វើអន្តរាគមន៍ឆ្ពោះទៅសម្រេចគោលដៅយុទ្ធសាស្ត្រ ៩៥% ទី១ ឱ្យទាន់ពេលវេលា។

៤) ស្នើឱ្យមានកិច្ចសហការពេញលេញពីក្រសួងមហាផ្ទៃ បន្តពង្រឹងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបង្កើនភាពម្ចាស់ការក្នុងការឆ្លើយតបនឹងជំងឺអេដស៍ នៅតាមមូលដ្ឋានរបស់ខ្លួនស្របតាមផែនការយុទ្ធសាស្ត្រជាតិ លើកទី៥ និងដោយមានជំនួយបច្ចេកទេសពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៥) ស្នើឱ្យមានកិច្ចសហការពេញលេញពីក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធ ក្នុងការពន្លឿនការអនុវត្តកិច្ចអន្តរាគមន៍ដើម្បីកាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។

៦) ស្នើឱ្យមានកិច្ចសហការពេញលេញពីក្រសួងផែនការ ក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត អង្គការ UNAIDS និងដៃគូពាក់ព័ន្ធដែលបានធ្វើឱ្យសម្រេចនូវការផ្តល់ប័ណ្ណសមធម៌ ជាលក្ខណៈបុគ្គលដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍គ្រប់គ្នានៅកន្លែងផ្តល់ឱសថប្រឆាំងមេរោគអេដស៍។

៧) ដាក់ឱ្យផ្សព្វផ្សាយ និងអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យការអនុវត្តលិខិតលេខ២១៣ សជណ.សស ស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

៨) ស្នើគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ ត្រូវតែចូលរួមបន្តសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល តាមយន្តការនានាក្នុងវិស័យរៀងៗខ្លួន៕

ថ្ងៃចន្ទ ១រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១

**ប្រធានអង្គប្រជុំ**
**ទេសរដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង_មូលី**